ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៨

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....០០២....សហវ.ពដ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០០៧

អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធករ របស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបប្រព័ន្ធស្វ័យប្រកាស (របបពិត) ទាំងអស់ មេត្តាជ្រាបថា លោក-លោកស្រីមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធក្នុងរយៈវេលា ៣ខែ ក្រោយពីដំណាច់ឆ្នាំ ។ សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០០៧ នេះ លោក-លោកស្រីត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៨ ។

ចំពោះសហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារវាងគ្រឹះស្ថានជាគោលដើមនិងសាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវគណនីលទ្ធផលរបស់សាខានីមួយៗ ។ ដោយឡែកសម្រាប់សាខានីមួយៗ ត្រូវដាក់ច្បាប់ចម្លងនៃលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើម និងគណនីលទ្ធផលរបស់សាខាដែលជាប់ទាក់ទិនជូនរដ្ឋបាលសារពើពន្ធដែលសាខាទាំងនោះតាំងនៅ ។

កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យឃើញថាសហគ្រាសមួយចំនួនមិនបានដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំបានត្រឹមត្រូវគ្រប់គ្រាន់តាមខ្ទង់នីមួយៗឡើយ ។ ចំណុចខ្វះខាតដែលតែងតែពិនិត្យឃើញជាប្រចាំ គឺសហគ្រាសមិនបានបំពេញឱ្យបានត្រឹមត្រូវនូវព័ត៌មានអំពីការចូលរួមមូលធន ព័ត៌មានអំពីនិយោជិកនៅក្នុងការិយបរិច្ឆេទក្នុងទំព័រទី ២ តារាងគណនាពន្ធលើប្រាក់ចំណេញក្នុងទំព័រទី ៩ និងទី ១០ និងការកែតម្រូវឥណទានខាតយោងទៅមុខក្នុងទំព័រទី ១២ ក្នុងករណីដែលមានការកំណត់លទ្ធផលឡើងវិញដោយសវនករពន្ធដារ ។

ដើម្បីបង្កភាពងាយស្រួលដល់ការដាក់លិខិតប្រកាសនេះ នាយកដ្ឋានពន្ធដារបានរៀបចំនូវសៀវភៅពន្យល់ណែនាំក្នុងការបំពេញលិខិតប្រកាសនិងទំរង់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំតាមប្រព័ន្ធ software ។ ក្នុងករណីដែល លោក-លោកស្រី មានចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ឬចង់បានសៀវភៅពន្យល់ណែនាំ និងលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំតាមប្រព័ន្ធ software សូមទាក់ទងជាមួយផ្នែកសេវាអ្នកជាប់ពន្ធនៅតាមការិយាល័យឬសាខាពន្ធដារខេត្ត/ក្រុងរបស់នាយកដ្ឋានពន្ធដារ ។

ការមិនបានដាក់លិខិតប្រកាស ការដាក់លិខិតប្រកាសមិនទាន់ពេលវេលា ឬមិនត្រឹមត្រូវ នឹងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣០ ដល់មាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជា អភិបាល បណ្ណាធិការ ឬកម្មសិទ្ធករសហគ្រាសដែលស្ថិតក្រោមការគ្រប់គ្រងប្រមូលពន្ធតាមរបបស្វ័យប្រកាស ពិតជាយកចិត្តទុកដាក់អនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ ។/.

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com